ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Apr-2015, 14:13
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

# សាធារណៈ–កោសល្លុប

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៥៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

កញ្ញា ជា ស៊ីវហ៊ាង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆរ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សួន វិសាល | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ាន់ សឿន ហៅ ស៊ាន់ (2-TCW-847) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ម៉ាន់ សឿន ហៅ ស៊ាន់** (2-TCW-847)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................................................................ទំព័រ ៤
សួរដោយលោក សួន វិសាល ផ្តើមពី ..........................................................................ទំព័រ ១៨
សួរដោយលោក គង់ សំអុន ផ្តើមពី ...........................................................................ទំព័រ ២១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅព្រឹកនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី វ៉ាន់ សឿន ដោយសហមេធាវីការពារក្តី។ ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការព្រឹកនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោក អាកទូរ វែកគែន មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមាន ដោយលោកមានបញ្ហាសុខភាព។ លោកស្រី ទូច វរល័ក្ស មេធាវីជាតិប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន បានជូនដំណឹងមកថា នឹងមកយឺតបន្តិចនៅព្រឹកនេះ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺលោក វ៉ាន់ សឿន លោកនិងមេធាវីប្រឹក្សាលោក ម៉ម រិទ្ធា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

សូមអរគុណលោកប្រធាន។

[០៩:០៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ស៊ីវហ័ង។

បាទ អង្គជំនុំជម្រះសម្រេចលើបណ្តឹង -- លើពាក្យសុំរបស់លោក នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ

មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្ដីរបស់គាត់បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥។ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះមានអាការៈឈឺចង្កេះ មិនអាចអង្គុយយូរបាន និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិក្នុងកិច្ចដំណើរការសវនាការនេះផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៧:៣៨]

អង្គជំនុំជម្រះមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី សូមបញ្ជាក់សាជាថ្មីទៀត ក៏ដូចជាការជូនដំណឹងទៅដល់សាធារណជនជ្រាប។ កាលពីរសៀលម្សិលមិញក្រោយពីប្រជុំពិភាក្សារយៈពេល ២០នាទី អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនៃរឿងក្ដីទាំងនេះហើយថា នៅពេលបញ្ចប់ការស្ដាប់សក្ខីកម្មសាក្សី វ៉ាន់ សឿន នេះទៅអង្គជំនុំជម្រះនឹងមិនធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-803 នៅរសៀលនេះតាមកាលវិភាគដែលបានកំណត់នោះទេ។ ដោយអង្គជំនុំជម្រះនឹង

កំណត់កាលវិភាគសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-803 នៅពេលសមស្របនាពេលខាងមុខ។

ការណ៍ដែលអង្គជំនុំជម្រះសម្រេចផ្អាកមិនធ្វើសវនាការស្តាប់សក្ខីកម្ម 2-TCW-803 ដោយមូលហេតុថា សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ឯកសារថ្មីៗជាច្រើនជាបន្តបន្ទាប់ ជាហេតុធ្វើឲ្យភាគីពាក់ព័ន្ធដទៃទៀតមិនលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យអានឯកសារទាំងនោះ មុនពេលស្តាប់សក្ខីកម្មចំពោះសាក្សីជាក់លាក់មួយចំនួនដែលពាក់ព័ន្ធ។

ជាការជំនួសអង្គជំនុំជម្រះនឹងធ្វើកិច្ចប្រជុំរៀបចំសវនាការ ដើម្បីពិភាក្សាលើបញ្ហាដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការដែលសហព្រះរាជអាជ្ញាអន្តរជាតិដាក់ឯកសារថ្មីៗជាបន្តបន្ទាប់នេះ។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីបម្រុង សាក្សី TCW-803 បើសិនបើមិនទាន់បញ្ជូនទៅទេ គឺបញ្ជូនគាត់ត្រឡប់ទៅកាន់លំនៅដ្ឋានគាត់វិញចុះ ហើយនិងឲ្យរង់ចាំទទួលការបង្គាប់ និងការកំណត់កាលបរិច្ឆេទសម្រាប់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះជាថ្មីនាពេលខាងមុខ។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ បាទ សូមអញ្ជើញបាទ!

[០៩:០៩:៥៥]

**លោក វិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម អស់លោកទាំងអស់។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមសាកសួរ ដោយបង្ហាញជូនសាក្សីនេះនូវគំនូរព្រាងមួយ។ គំនូរនេះ គឺគូរឡើងដោយសាក្សី ស្រី តាន់ នៅចំពោះមុខ -- ស្រី ថន នៅចំពោះមុខ ឯកសារ D125/129 អង់គ្លេសមានលេខ 0021167, ខ្មែរមានលេខ00 -- 00224792។ បាទ សូមអភ័យទោស ខ្ញុំមិនមាន ERN ជាភាសាខ្មែរទេ ប៉ុន្តែឯកសារនេះគឺត្រូវបានពិភាក្សាជាញឹកញាប់រួចមកហើយ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដាក់បង្ហាញនៅលើអេក្រង់ និងបង្ហាញឯកសារ និងជូនឯកសារនេះទៅសាក្សី។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដាក់នៅលើអេក្រង់ តើបានទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:១០:៣៣]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីសូមលោកពិនិត្យមើលទៅលើគំនូរព្រាងនេះ ហើយខ្ញុំចង់ឲ្យលោកពិនិត្យលម្អិតបន្តិចទៅលើគំនូរនេះ។ តើលោកអាចប្រាប់យើងខ្ញុំបានទេ ថាតើអ្វីដែលគូរហ្នឹងជាការរៀបរាប់ត្រឹមត្រូវនៅក្នុងបរិវេណផ្ទៃក្នុងនៃក្រាំងតាចាន់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ជម្រាបសួរលោកប្រធាន សូមអរគុណ។ ដើម្បីកុំឲ្យសាក្សីយល់ច្រឡំ ខ្ញុំមិនជំទាស់ទេ ក៏ប៉ុន្តែផែនទីនេះ គឺថាបង្ហាញខុសពីធម្មតា ពីទម្លាប់ធម្មតា ព្រោះថាទិសខាងជើង មិនមែននៅខាងជើង នៅខាងលើទេ តែនៅខាងក្រោមវិញ។ អ៊ីចឹងសូមឲ្យពន្យល់ប្រាប់សាក្សី ឲ្យយល់ថាធម្មតាខាងជើងនៅខាងលើ កាលណាយើងគូសរូប ហើយខាងត្បូងនៅខាងក្រោម។ នេះទៅបញ្ច្រាសហើយលោកប្រធាន។ អ៊ីចឹងសូមឲ្យលោកសាក្សី គាត់មើលពិពណ៌នាទៅតាមផែនទីបញ្ច្រាសហ្នឹង។

[០៩:១៣:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំឯកភាព។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយសាក្សីនៅពេលដែលលោកពិនិត្យសូមលោកចងចាំផងថា អ្នកដែលគូសផែនទីនេះគឺគាត់គូសដាក់ទិសខាងជើងមកខាងក្រោមវិញ ហើយទិសខាងត្បូងបញ្ច្រាសឡើងមកលើ។ ដូច្នេះតើលោកសាក្សីអាចពិនិត្យមើលបានទេ? ឥឡូវនេះតើលោកអាចជម្រាបជូនមកអង្គជំនុំជម្រះថាតើការគូរ

ហ្នឹង ជាគូរបង្ហាញត្រឹមត្រូវអំពីបរិវេណនៃក្រាំងតាចាន់ដែរឬទេ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ គូរនេះគឺខុស បើគូសលិច កើត ជើង ត្បូង ហ្នឹងអាចយល់បាទ។

**ស៖** ខ្ញុំយល់ស្របជាមួយលោក លោកសាក្សី។ ខ្ញុំយល់ស្របថាទិសវាសុខអ៊ីចឹងមែន។ ប៉ុន្តែលោកនិយាយថា វាមិនត្រឹមត្រូវទាំងអស់។ តើលោកអាចមើលម្តងទៀតមើលថា តើអ្វីដែលមិនត្រឹមត្រូវដែលលោកថាមិនត្រឹមត្រូវហ្នឹង តើមានអ្វីសូមលោកបញ្ជាក់ឡើងវិញ?

**ឆ៖** បាទ ពីព្រោះផ្លូវចូល វានៅតាមជ្រុងទៅវិញបាទ។

[០៩:១៥:០៣]

**ស៖** សូមអរគុណ។ សាក្សីមានអ្វីផ្សេងទៀតដែលមិនត្រឹមត្រូវ ដែលលោកអាចប្រាប់បាន? ចំពោះការគូរហ្នឹងមានអ្វីទៀតដែលវាមិនត្រឹមត្រូវ?

**ឆ៖** បាទ គូរចន្លោះផ្លូវចូល និងៗផ្លូវចេញបាទ។ មានផ្លូវចូលផ្លូវចេញ និងបន្ទប់ បាទ។

**ស៖** តើលោកអាចប្រាប់បានទេថាចំពោះអគារវិញ តើវាខុសត្រង់ចំណុចណាខ្លះ?

**ឆ៖** បាទ ផ្លូវចូលវាលិចកើត អគារនៅស្របផ្លូវពីខាងជើងផ្លូវ បាទ។ ហើយបន្ទប់ខាងត្បូង និងរោងបាយនៅប៉ែកខាងត្បូវផ្លូវហើយ។

**ស៖** ចុះបន្ទប់សួរចម្លើយ ធៀបជាមួយនឹងបន្ទប់សម្រាប់ឃុំខ្លួន តើលោកឃើញថាយ៉ាងម៉េចដែរ? វាមានលក្ខណៈយ៉ាងម៉េចដែរ?

**ឆ៖** បាទ បន្ទប់ឃុំខ្លួននៅខាងជើងផ្លូវ បន្ទប់សួរចម្លើយនៅខាងត្បូងផ្លូវ។

**ស៖** ចុះទីកន្លែងដែលសួរចម្លើយអ្នកទោសហ្នឹង តើវាមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** បាទ នៅខាងត្បូងផ្លូវចម្ងាយ៣០ម៉ែត្រ បាទ។

**ស៖** លោកសាក្សីកាលពីម្សិលមិញនៅពេលដែលខ្ញុំបញ្ចប់ -- រៀបបញ្ចប់សំណួររបស់ខ្ញុំគឺយើងពិភាក្សាអំពីវ៉ាដ្ស ហើយនិងៗ អុបប៉ាល័រដោះដាក់។ តើលោកអាចប្រាប់បានដែរឬទេថា វ៉ាដ្ស ឬក៏អំភ្លី ឬក៏ធុងបាសហ្នឹង គេដាក់នៅកន្លែងណាដែរ? តើគេទុកនៅម្តុំណាដែរនៅក្រាំងតាចាន់នោះ?

**ឆ៖** បាទ វ៉ាដ្សហ្នឹង គេទុកនៅកន្លែងប្រធានផ្ទាល់តែម្តងបាទ។

[០៩:១៨:០០]

**ស៖** ចុះបន្ទប់ប្រធានហ្នឹងនៅកន្លែងណា?

**ឆ៖** បាទ នៅចំណុចកណ្ដាល។

**ស៖** ឥឡូវនេះយើងបន្តបន្តិចទៅលើរឿងធុងបាសនោះ។ ម្សិលមិញលោកបានប្រាប់ពីទំហំនៃធុងបាសនៃអុបប៉ាល័រនោះ។ ដូច្នេះដើម្បីឲ្យច្បាស់ ថាតើមានបង្គោល ឬក៏មានសរសរអីដែលគេអាចដាក់ធុងបាស ឬក៏អុបប៉ាល័រហ្នឹង ដើម្បីឲ្យវាឮសំឡេងខ្លាំង វាសាយភាយខ្លាំងដែរទេ? តើមានជាបង្គោល ឬក៏សរសរអីបែបនេះទេ?

**ឆ៖** អត់ៗទេ ដាក់លើតុតែម្ដងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំចង់ឲ្យលោកមើលទៅបន្ទប់ឃុំខ្លួនអ្នកទោស នៅក្នុងរូបគំនូរនេះ។ កាលពីម្សិលមិញយើងបាននិយាយអំពី យាយញ៉ ហើយនិងកូនស្រីរបស់គាត់ គឺឈ្មោះវ៉ាត់ ឬក៏ សាវ៉ាត់ ហ្នឹង។ តាមដែលខ្ញុំយល់ពីសក្ខីកម្មរបស់លោក អ្នកទោសទាំងពីររូបនេះ គឺថាតាមដែលលោកចាំ តើស្ត្រីទាំងពីររូបហ្នឹងគេឃុំខ្លួននៅកន្លែងណាដែរ? ហើយចុះពេលយប់តើពួកគាត់សម្រាកនៅកន្លែងណាដែរ?

[០៩:២០:០០]

**លោក វ៉ាងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំ គឺខ្ញុំជំទាស់នឹងសំណួរនេះ។ សាក្សីបាននិយាយច្បាស់ហើយថាមានអគារបីហើយនៅក្នុងបន្ទប់នេះ ដែលធ្វើដោយ ស្រី ថន ហៅ ឌុច នុ៎ង មានតែអគារពីរទេ។ អ៊ីចឹងសំណួរចង់ដឹងថាតើអគារទាំងពីរហ្នឹង អ្នកទោសនៅក្នុងអគារណា នៅក្នុងចំណោមអគារទាំងពីរនេះ? វាមិនមែនជាអ្វីដែលសាក្សីបាននិយាយកាលពីម្សិលមិញនោះទេ។ ព្រោះថាម្ខាងមានគឺ ឌុច និយាយថាមានពីរ អគារពីរ ហើយគាត់ថាបី ហើយថាមួយចាស់ជាងគេ។ អ៊ីចឹងខ្ញុំសូមឲ្យគាត់ហ្នឹងរៀបចំសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះយើងមិនបាច់មើលរូបគំនូរក៏បានដែរ។ ប៉ុន្តែលោកសាក្សីតាមដែលលោកចាំ តើ វ៉ាត់ ហើយនិង យាយញ៉ ហ្នឹង គេឃុំខ្លួននៅអគារមួយណាដែរនៅក្នុងបរិវេណក្រាំងតាចាន់នោះ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ លោក យាយញ៉ និង សាវ៉ាត់ ហ្នឹងឃុំខ្លួននៅបន្ទប់ទី២បន្ទាប់ពីផ្លូវចូលខាងត្បូងបាទបន្ទប់នៅទន្ទឹមគ្នាបាទ។

[០៩:២១:៤០]

**ស៖** នៅពេលដែលលោកនិយាយថា "ឃុំ" តើលោកចង់និយាយ ឃុំហ្នឹង ឃុំតែពេលព្រឹក ឬក៏ឃុំទាំងពេលព្រឹក ឬក៏ទាំងយប់ទាំងព្រឹក?

**ឆ៖** បាទ លោកយាយញ៉ ហ្នឹង ហើយ សារ៉ាត់ ហ្នឹងគេដាក់តែពេលយប់ទេបាទ ថ្ងៃគាត់ចេញធ្វើការ បាទ។

**ស៖** តើលោកចាំទេថា ពួកគាត់នៅជាមួយគ្នានៅពេលយប់ នៅពេលដែលគេឃុំខ្លួន ឬក៏ពួកគាត់នៅដាច់ពីគ្នានៅពេលយប់?

**ឆ៖** បាទ អត់មានដាក់ចូលគ្នាទេបាទ។

**ស៖** លោកអាចពន្យល់បន្ថែមបន្តិចបានទេ ថាលោកនិយាយថា ពេលខ្លះពួកគេអត់នៅជាមួយគ្នា។ តើលោកចាំថា យ៉ាងម៉េចដែរអំពីបញ្ហានេះ? គឺថា តើលោកចាំថាយ៉ាងម៉េចដែរ នៅពេលដែលលោកនិយាយទាំងអស់ និយាយបញ្ហាទាំងអស់នេះមក?

**ឆ៖** ខ្ញុំមិនដឹងថា និយាយថាម៉េចដែរ ពីព្រោះថាមួយទៅមុន មួយទៅក្រោយ ហើយការស្លាប់បាត់បង់ តាគុណ មុនបាទ។ ហើយក៏គ្រួសារទៅក្រោយ គេដាក់ក្រោយតែម្តងបាទ។

[០៩:២៣:១៦]

**ស៖** លោកសាក្សីជួយពន្យល់ខ្ញុំបន្តិច តើយ៉ាងម៉េចដែរ? ព្រោះថាតាមសក្ខីកម្មកន្លងមក គឺថាអ្នកទាំងពីរហ្នឹងគឺឃុំខ្លួននៅពេលជាមួយគ្នា គឺអស់រយៈពេលប្រហែល២ឆ្នាំកន្លះ។ តើលោកយល់ឃើញ -- តើលោកចាំថាអ៊ីចឹងដែរ ឬមួយក៏លោកចាំផ្សេងពីនេះ?

**ឆ៖** បាទ រយៈពេលឃុំខ្លួនហ្នឹងពិតជាអ៊ីចឹងមែនបាទ។

**ស៖** ខ្ញុំគ្រាន់តែចង់សួរព័ត៌មានលម្អិត អំពីថាតើពួកគាត់នៅទីណាដែរនៅពេលយប់? ថាតើគេមានដាក់ខ្នោះជើងឬក៏អត់? ខ្ញុំចង់ឲ្យមានព័ត៌មានលម្អិតបន្ថែមបន្តិចទាក់ទងនឹងអ្វីដែលគាត់ធ្វើនៅពេលថ្ងៃ? លោកអាចពន្យល់ប្រាប់ខ្ញុំបានទេពីចំណុចទាំងអស់នេះ?

**ឆ៖** បាទ ពេលយប់ខ្ញុំមិនដឹងដែរបាទ ខ្ញុំនៅក្រៅ បាទ។

**ស៖** ខ្ញុំយល់ថា យាយញ៉ ភាគច្រើនគាត់ជាអ្នកធ្វើម្ហូបឲ្យអ្នកទោស ចុះកូនស្រីគាត់គឺ រ៉ាត់ ហ្នឹងជួយគាត់នៅពេលដែលចម្អិតម្ហូបដែរ ឬក៏អត់ទេ?

**ឆ៖** បាទ។

**ស៖** តើគាត់រវល់ចម្អិនម្ហូបពេញ១ថ្ងៃ ឬក៏គាត់ចម្អិនតែ -- គាត់មានពេលទំនេរខ្លះដែរ?

**ឆ៖** បាទ ពេលព្រឹកមួយពេល ថ្ងៃល្ងាចមួយពេលបាទ។

**ស៖** នៅក្នុងរយៈពេល២ឆ្នាំកន្លះដែលស្ត្រីពីររូបនេះត្រូវបានគេឃុំនៅក្រាំងតាចាន់ ហើយគាត់មានការងារជាអ្នកធ្វើម្ហូបនោះ។ តើលោកធ្លាប់ជជែកលេង -- តើលោកធ្លាប់ជជែកលេងជាមួយ វ៉ាត់ ដែរឬទេ?

**ឆ៖** បាទ ធ្លាប់និយាយលេងដែរបាទ។

**ស៖** តើលោកចាំទេថា ពេលដែលលោកនិយាយលេងជាមួយ វ៉ាត់ ហ្នឹង លោកនិយាយអំពីអ្វីដែរ?

**ឆ៖** បាទ និយាយធម្មតា លេងសើចហ្នឹងបាទ។

**ស៖** តើលោកចាំទេថា វាមានអ្វីមិនល្អកើតឡើងចំពោះ វ៉ាត់ នៅពេលដែល វ៉ាត់ ជាប់ឃុំនោះដែរឬទេ?

**ឆ៖** បាទ ក្នុងអំឡុងហ្នឹង គ្មានពេលអាក្រក់ទេ ពីព្រោះថា យាយញ៉ៃ ហើយនិង វ៉ាត់ ខ្ញុំហ្នឹងដូចថា ដូចជារាប់គ្នាទៅហើយបាទ។ គាត់ហៅខ្ញុំតែកូនៗទេបាទ។

[០៩:២៦:៥១]

**ស៖** បាទ ខ្ញុំចង់សួរឲ្យលម្អិតបន្តិច តើលោកដឹងដែរឬទេថា វ៉ាត់ ត្រូវបានកម្មាភិបាល ឬក៏សន្តិសុខហ្នឹងធ្វើការប៉ះពាល់ផ្នែករាងកាយដែរឬទេ?

**ឆ៖** បាទ ត្រង់ចំណុចនេះ ខ្ញុំអត់ដឹងដែរបាទ។

**ស៖** [redacted]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា អង្គជំនុំជម្រះបានអនុម័តវិធានមួយហើយ ដែលតម្រូវឲ្យយើងប្រុងប្រយ័ត្នមែនទែន ពេលដែលយើងនិយាយអំពីដែលជាជនរងគ្រោះពីការរំលោភបំពានផ្លូវភេទនៅក្នុងរយៈពេលដែលយើងកំពុងតែពិភាក្សាគ្នានេះ ដែលយើងថាយើងកុំឲ្យនិយាយជាសាធារណៈ។ ដូច្នេះ យើងឲ្យជាឯកសារមួយទៅសាក្សីទៅ ជាការសម្ងាត់ជាង។ ហើយបើអ៊ីចឹង ខ្ញុំសូមឲ្យមេធាវី

ការពារក្ដីគោរពការណែនាំរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងការសួរសំណួរទៅសាក្សីទាក់ទងនឹងការរំលោភផ្លូវភេទនេះ។

[០៩:២៨:២៥]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។ ជាទូទៅ ខ្ញុំគិតថា ហេតុអ្វីបានជាយើងមិនអាច -- យើងគួរតែបែងចែកភាពខុសគ្នានៅពេលដែលយើងសួរសំណួរ។ ឧទាហរណ៍ដូចជា ការស៊ីគ្រឿងក្នុងមនុស្ស ការសម្លាប់ជាទ្រង់ទ្រាយធំ ធៀបជាមួយនឹងការវាយប្រហារលើផ្លូវភេទ ឬក៏ការរំលោភផ្លូវភេទ ព្រោះទាំងអស់ហ្នឹងសុទ្ធតែជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ហេតុអីក៏ចាំបាច់មានការបែងចែកឲ្យខុសគ្នាអ៊ីចឹងធ្វើអី។ ហើយទី២ យើងក៏មិនដឹងថា តើ វ៉ាត់ គាត់ព្រួយបារម្ភ ឬក៏មិនព្រួយបារម្ភអំពីឯកជនភាពរបស់គាត់ បែបនោះទេ។ ដូច្នេះ ជាជាងការដែលយើងនិយាយមិនច្បាស់លាស់អំពីការព្រួយរបស់អ្នកដទៃទាក់ទងទៅនឹងភាពឯកជនរបស់អ្នកដទៃហ្នឹង ខ្ញុំគួរតែបន្តទៅមុខ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះយល់ពីនេះផ្សេងប្រហែលជាខ្ញុំស្នើសុំផ្សេងពីនេះ។ ព្រោះថាចំណុចទាំងអស់នេះ គឺវាពាក់ព័ន្ធទៅលើភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានចំពោះសាក្សីនីមួយៗ។ ដូច្នេះ ខ្ញុំគួរតែមានឱកាសសួរសំណួរទាំងនេះ។

[០៩:២៩:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៩:០១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញាទៅលើសំណួរសួររបស់មេធាវីការពារក្ដី នួន ជា ចំពោះសាក្សី។

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដំបូងនិងជារួម គឺអង្គជំនុំជម្រះចេញនូវសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងការការពារភាពជាឯកជនពាក់ព័ន្ធទៅនឹងការរំលោភផ្លូវភេទ។ ពាក់ព័ន្ធទៅនឹងការតាំងសំណួរក្នុងពេលនេះ អង្គជំនុំជម្រះនឹងពិនិត្យមើលប្រតិចារឹក។ ហេតុដូច្នេះ បង្គាប់ឲ្យមេធាវីការពារក្ដី គឺរហូតដល់ពេលសម្រាកគឺត្រូវតែគោរពទៅតាមការតាំងសំណួរ ហើយសូមបន្តចូលប្រធានបទផ្សេងទៀតចុះ។

**លោក វិុចទ័រ កូប៉េះ**

មិនជាបញ្ហាអ្វីទេ លោកស្រីចៅក្រម។

**សួរដោយលោក វិុចទ័រ កូប៉េះ**

**ស៖** លោកសាក្សី នៅត្រង់កៅអីដែលលោកកំពុងអង្គុយនេះ អតីត ឌុចតួច ក៏បានអង្គុយនៅលើកៅអីជាមួយលោកកំពុងអង្គុយនេះដែរ។ ហើយខ្ញុំបានសួរគាត់នូវសំណួរតឹងរ៉ឹងមួយចំនួន គឺដោយយោងទៅលើសក្ខីកម្មរបស់ សយ សែន។ សយ សែន បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថា ឌុច ហើយនិងសមមិត្តរបស់គាត់នោះបានចូលរួមពាក់ព័ន្ធនៅក្នុងការសម្លាប់ក្មេងៗ ការរំលោភបំពានផ្លូវភេទក៏ដូចជាការរំលោភសេពសន្ថវៈ ការសម្លាប់ទ្រង់ទ្រាយធំជាដើម ។ល។ នៅពេលដែលប្រឈមមុខទៅនឹងសក្ខីកម្មនេះ ឌុច បានឆ្លើយថាគឺ សយ សែន បានផ្តល់សក្ខីកម្ម ខ្ញុំសូមដកស្រង់ "គឺជាការបំផ្លើស"។ សំណួររបស់ខ្ញុំចំពោះលោកគឺសូមសួរដូចតទៅ តើលោកមានប្រតិកម្មថាម៉េចដែរ ចំពោះសក្ខីកម្មរបស់ ឌុច ចំពោះចម្លើយរបស់ ឌុច ដែល សយ សែន ឆ្លើយថា ចម្លើយហ្នឹងគឺជាចម្លើយបំផ្លើសទេ មិនពិតទេ។ តើលោកមានប្រតិកម្មដូចម្តេចដែរ?

[០៩:៤១:៥៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំជំទាស់នឹងសំណួរនេះ។ ម្សិលមិញនោះ ខ្ញុំគួរតែជំទាស់ដែរទៅនឹងសំណួរដែលសួរទៅសាក្សីថា តើ សយ សែន ហ្នឹងបានកុហកដែរឬក៏អត់? ខ្ញុំគិតថា សាក្សីនេះមិនអាចដឹងថា សយ សែន នេះនិយាយយ៉ាងណាយ៉ាងណីនោះទេ ពីព្រោះថា សយ សែន គាត់បានឃើញអ្វីផ្សេងទៀតដែលគាត់បានឃើញ បានទៅកន្លែងផ្សេងទៀតនៃមន្ទីរឃុំឃាំងហ្នឹង។ គាត់អាចឡើងទៅលើដាក់ឆ្នោត គាត់អាចកាលនោះកប់សាកសពជាដើម។ អ៊ីចឹងអ្វីដែលខុសពីអ្វីដែល -- ខុសពីសាក្សីយើងនៅទីនេះ គាត់អត់បានធ្វើការងារដូច សយ សែន ទេ។ អ៊ីចឹងសួរឲ្យគាត់ទៅធ្វើការវាយតម្លៃលើសក្ខីកម្មរបស់ សយ សែន នោះមិនអាចធ្វើទៅបានទេ ព្រោះថាគាត់មិនបានឃើញ ឬក៏ឆ្លងកាត់អ្វីដែលដូចគ្នានឹង សយ សែន នោះទេ។ អ៊ីចឹងឧទាហរណ៍ដូចសួរថា តើ សយ សែន កុហក ឬក៏មិនកុហកនោះ មិនត្រឹមត្រូវទេ មិន

អាចជួយឲ្យយើងរកឃើញការពិតបានទេ។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះបដិសេធសំណួរនេះ លោកប្រធាន។

[០៩:៤៣:២៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំ -- លោកប្រធាន ខ្ញុំមិនដឹងថាមានប្រតិកម្មយ៉ាងម៉េចទៅនឹងតំណាងសហព្រះរាជអាជ្ញានោះទេ ប៉ុន្តែខ្ញុំស្នើសុំជាទូទៅតែម្ដងថា វាជាពេលវេលាមួយដែលភាគីទាំងអស់ ក៏ដូចជាអង្គជំនុំជម្រះត្រូវទៅពិនិត្យមើលទីតាំងឧក្រិដ្ឋកម្មក្រាំងតាចាន់ ដើម្បីឲ្យយល់ទាំងអស់គ្នា។ វាជាទីតាំងមួយតូចទេ។ ហើយខ្ញុំកំពុងតែបង្ហាញភស្តុតាងហ្នឹងហើយ ក៏ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវបានឃើញទីតាំងនោះក៏បានដឹងហើយនិងធៀបទៅនឹងសក្ខីកម្មរបស់ សយ សែន។ ប៉ុន្តែពេលខ្លះ សយ សែន អាចនឹងឆ្លើយទាំងមិនយកចិត្តដាក់ថាសាក្សីរូបនេះគឺមិនអាចមើល មិនអាចឃើញអ្វីដូចគាត់ថានោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដោយសារលោកនិយាយចំណុចនេះ ថាតើលោកមានសំណើសុំ ឬក៏អត់ទេ? ដោយសារវាមិនច្បាស់លាស់អ៊ីចឹង សូមផ្ដល់មូលហេតុមកផង ដើម្បីអនុញ្ញាតឲ្យមានសេចក្ដីសម្រេច។

[០៩:៤៤:៥៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

ការជំទាស់នេះ អាចធ្វើឲ្យខ្ញុំធ្វើការដាក់ជាសំណួរមួយ ដែលថាយើងទាំងអស់នេះអាចទៅពិនិត្យមើលកន្លែងនោះមើល។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើឥឡូវនេះខ្ញុំសួរទៅលោក ថាតើលោកស្នើសុំឲ្យទៅពិនិត្យទីតាំង ឬក៏អត់?

**លោក វ៉ិចទ័រ កូប៉េះ៖**

ដោយសារលោកស្រីសួរខ្ញុំក្នុងពេលមួយខ្លីបែបនេះ គឺថាខ្ញុំដើម្បីឲ្យជឿជាក់បាន ហើយវាសំខាន់ផងដែរ ដែលថាឲ្យអនុញ្ញាតឲ្យមេធាវីការពារក្ដីទៅពិនិត្យមើលទីតាំងនោះតែម្ដង ដើម្បីឲ្យយល់មើលថាតើសក្ខីកម្មវាខុសគ្នាយ៉ាងរបៀបម៉េច ប្រៀបធៀបទៅនឹងជើងភ្នំ ទៅមើលវាលស្រែនៅជុំវិញទីតាំង

នោះ ទៅមើលអគារ។ បើធ្វើដូច្នេះគឺថា បើមិនដូច្នេះទេគឺថាការជំទាស់នេះ មិនមានន័យអ្វីទេ គឺត្រូវតែសម្រេចមធ្យោបាយណាមួយ។ ខ្ញុំមិនមែនលើកឡើងថា សាក្សីរូបនេះ ឬក៏សហការីរបស់គាត់មិនអាចជម្រាបអង្គជំនុំជម្រះបានទេ ដោយសារថា មានគេនិយាយថា មានសាក្សីឃើញការសម្លាប់រាប់រយពាន់នាក់ មានរណ្ដៅ ហើយក៏មានធុំក្លិនសាកសពដែលស្អុយនោះ។ ដូច្នេះជំហររបស់យើងខ្ញុំ ថាតើ សយ សែន ឬក៏មិនដឹង សយ សែន ឬ មាស សុខា ទេ មួយណាដែលជាអ្នកនិយាយកុហកនោះទេ។ ការដែលខ្ញុំលើកឡើងបែបនេះ ដូច្នេះសំណើសុំរបស់ខ្ញុំ គឺថាយើងទាំងអស់គួរតែធ្វើដំណើរ មិនឆ្ងាយផងទៅមើលមន្ទីរសន្តិសុខក្រាំងតាចាន់តែម្ដងទៅ។

[០៩:៤៦:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងក៏បានទៅក្រាំងតាចាន់ ខ្លួនឯងដែរ ហើយយើងមិនទាញការសន្និដ្ឋានដូចមេធាវីការពារក្ដីនោះទេ ព្រោះជាការទាញការសន្និដ្ឋានលម្អៀង ហើយនិងអត្តនោម័តិ ហើយឃើញថា គាត់ថា -- បើគិតថា សាក្សី -- គាត់យល់ឃើញថា សាក្សីនេះមិន -- គាត់ថាដូចមិនកុហក ឬក៏កុហក តើគាត់ហ្នឹង គាត់បានប្រាប់ហើយថា គាត់ជាអ្នកយាមនោះទេនៅមន្ទីរក្រាំងតាចាន់។ អ៊ីចឹងខ្ញុំមិនជំទាស់អីនឹងអ្វីដែលខាងការពារក្ដីធ្វើទេ។ ក៏ប៉ុន្តែអង្គជំនុំជម្រះមានព័ត៌មានគ្រប់គ្រាន់ក្នុងការវិភាគលើព័ត៌មាន ឬក៏ការពិតដែលសាក្សីនេះផ្ដល់ឲ្យ។ ខ្ញុំគិតថា បើទោះបីជាគាត់មិនបានឃើញអ្វីក៏ដោយ ក៏មិនមែនបានន័យថា គាត់មិនបានឃើញ គាត់មិនបានដឹងនោះទេ ព្រោះគាត់អ្នកយាមនៅទីនោះដែរ។

[០៩:៤៨:១២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តំណាងសហព្រះរាជអាជ្ញា ឥឡូវនេះយើងមានសំណើសុំជាផ្លូវការហើយ។ ខ្ញុំស្នើសុំឲ្យលោកតើលោកមានមតិយ៉ាងម៉េចដែរ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំមិនមានគំនិតយោបល់អីពិសេសទេ ក៏ប៉ុន្តែជាទូទៅ យើងថាទៅមើលផ្ទាល់នឹងកន្លែងដើម្បីឲ្យដឹងថាទ្រង់ទ្រាយកន្លែងនោះយ៉ាងម៉េចដែរកាលពីសម័យនោះ ក៏ប៉ុន្តែអ្វីដែលខ្ញុំដឹង គឺថាពុំមានអគារអ្វីនៅ

សល់នោះទេ នៅកន្លែងនោះនោះ។ អ៊ីចឹងខ្ញុំគ្រាន់តែថា ស្រេចតែលើអង្គជំនុំជម្រះសម្រេចតែប៉ុណ្ណោះ។ ក៏ប៉ុន្តែដើម្បីឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើងនេះ ខ្ញុំគិតថាខាងការពារក្តីភ្លេចអំពីតួនាទីជានីរសាររបស់សាក្សី។ អ៊ីចឹងបានន័យថា ពេលខ្លះគាត់មិននៅក្នុងកន្លែងនេះរហូតនោះទេ នៅមន្ទីរហ្នឹងរហូតទេ។ អ៊ីចឹងពេលខ្លះហ្នឹង គាត់ចេញទៅក្រៅហ្នឹង អ៊ីចឹងគាត់ -- ពេលខ្លះគាត់អាចមិនដឹងអំពីអ្វីដែលគេធ្វើនៅក្នុងមន្ទីរនោះទេ។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះសម្រេចទៅ យើងខ្ញុំពឹងផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះ។ បាទ សូមអរគុណ។

[០៩:៤៩:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥១:២៨]

**ប្រធានអង្គជំនុំ៖**

បាទទី១ អង្គជំនុំជម្រះសម្រេចព្យួរនូវសំណើសុំរបស់លោកមេធាវីការពារក្តី នួន ជា ដែលស្នើសុំទៅពិនិត្យនៅទីកន្លែងកើតហេតុ។ ជាក់ស្តែងនោះ អង្គជំនុំជម្រះនឹងពិចារណាសម្រេចបញ្ហានេះជាក្រោយ។ សម្រាប់បញ្ហាទី២ អង្គជំនុំជម្រះបដិសេធទទួលយកនូវការជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិលើសំណួរចុងក្រោយ គឺត្រឹមត្រូវ។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវី កូប៉េ ទេ។ ទី៣ លោកមេធាវី សូមលោកសួរទៅលើអង្គហេតុណាដែលសាក្សីដឹងបានហើយ ជៀសវាងសួរឲ្យសាក្សីឆ្លើយស្មានៗ ឬក៏សាក្សីឆ្លើយបែបសន្និដ្ឋាន វាយតម្លៃទៅលើសក្ខីកម្មសាក្សីដទៃទៀត។ ក្នុងនាមអ្នកជំនាញនោះ គឺជាកិច្ចការរបស់អង្គជំនុំជម្រះទេ ដែលត្រូវវាយតម្លៃថា សក្ខីកម្មណាពិត ឬមិនពិត នោះជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះដែលនឹងពិចារណាសម្រេចចុងក្រោយនៅក្នុងពេលដែលរៀបចំសាលក្រមប៉ុណ្ណោះ។

[០៩:៥២:៤៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំបន្តទៅប្រធានបទមួយផ្សេងទៀត ទោះវាពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ សយ សែន ម្តងទៀតក៏ដោយ។ ខ្ញុំសូមបង្ហាញលោកនូវបញ្ហាមួយចំនួនដែលគាត់បានឆ្លើយ ដែលថាគាត់មមាញឹកណាស់ធ្វើការរវល់ណាស់ នៅឯក្រាំងតាចាន់ហ្នឹង។ គាត់បានឆ្លើយជូនអង្គជំនុំជម្រះថា កិច្ចការរបស់គាត់មួយហ្នឹងគឺ ឧទាហរណ៍ដូចជារាប់ចំនួនអ្នកទោស ដែលត្រូវយកទៅសម្លាប់។ តើលោកដែល

ធ្លាប់បានឃើញ សយ សែន ត្រូវបានទទួលភារកិច្ចឲ្យវាប់អ្នកទោស មុននឹងគេយកអ្នកទោសហ្នឹងទៅសម្លាប់ចោលដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំគិតថាមេធាវីការពារក្តីហ្នឹង ត្រូវដកស្រង់អ្វីដែល សយ សែន និយាយឲ្យពេញលេញ កុំឲ្យបំភ្លៃរបស់គាត់ គឺថាមែនពេលនោះគាត់ទៅរាប់អ្នកទោស គាត់អត់បាននិយាយថា មុនពេលដែលយកទៅសម្លាប់ទេ បើតាមខ្ញុំចងចាំនោះ មិនមែនអ៊ីចឹងទេ។ សូមឲ្យមេធាវីការពារក្តីដកស្រង់ទាំងស្រុងនូវកំណត់ហេតុស្តាប់ចម្លើយរបស់ សយ សែន ឬក៏ប្រតិចារឹកនៅក្នុងសវនាការយើងនេះ ពីព្រោះថា កាលនោះខ្ញុំនៅទីនេះដែរ ហើយខ្ញុំមិនបានឮយ៉ាងដូច្នេះទេលោកប្រធាន។ អ៊ីចឹងសូមឲ្យគាត់ដកស្រង់ឲ្យបានពេញលេញ។

[០៩:៥៤:៤៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន លោក លោកស្រីចៅក្រម យើងបានស្តាប់សក្ខីកម្មរបស់ សយ សែន នៅចំពោះមុខអង្គជំនុំជម្រះ។ គាត់ក៏បានឆ្លើយនៅក្នុងចម្លើយជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីវាទៅមុខបានលឿន។ ខ្ញុំព្យាយាមនឹងផ្តល់ប្រតិចារឹកទាក់ទងទៅនឹងតួនាទី ភារកិច្ចដែលគាត់បានបំពេញ។ យើងបានស្តាប់ឮថា គាត់បានរាប់អ្នកទោសមុនយកសម្លាប់ចោល គាត់បានរាប់អ្នកទោសដែលគេដាក់ខ្នោះជើង គាត់បានសែងសាកសព គាត់បានយាមអ្នកទោសដែលធ្វើការនៅខាងក្រោយ គាត់បាននាំអ្នកទោសទៅកន្លែងដើមវិញក្រោយពេលសួរចម្លើយ គាត់ញ៉ុំងទឹក យួរទឹក រែកទឹក។ ដូច្នេះ ខ្ញុំគួរតែមានលទ្ធភាពផ្តល់នូវពាក្យពេចន៍ទូទៅរបស់គាត់ បន្ទាប់មកចាំនិយាយអំពីភារកិច្ច។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បញ្ហានោះគឺ តំណាងសហព្រះរាជអាជ្ញា គឺគាត់ជំទាស់ទៅនឹងការចងចាំរបស់លោក ហើយចង់ឲ្យយកប្រតិចារឹកនេះមកបង្ហាញតែម្តងថា សាក្សីហ្នឹងគឺនិយាយអ្វីដែលគាត់បាននិយាយ។

[០៩:៥៦:២២]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំបានសរសេរចូលក្នុងក្រដាសរបស់ខ្ញុំហើយ ខ្ញុំអាចសួរតាមរបៀបផ្សេងបានលោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី តើលោកដែលធ្លាប់បានឃើញ សយ សែន វាប់អ្នកទោសមុននឹងគេយកអ្នកទោសនោះទៅសម្លាប់ដែរទេ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ អត់ទេ។

**ស៖** លោកសាក្សី តើធ្លាប់ដែលឃើញ សយ សែន ដោះខ្នោះជើងអ្នកទោសចេញទេ មុនគេបណ្ដើរអ្នកទោសយកទៅសម្លាប់ចោល?

**ឆ៖** បាទ អត់ទេ។

**ស៖** លោកសាក្សី លោកដែលឃើញ សយ សែន ជីករណ្ដៅដើម្បីកប់សាកសពអ្នកទោសដែរទេ?

**ឆ៖** បាទ អត់ទេ។

[០៩:៥៧:២០]

**ស៖** លោកសាក្សី លោកដែលឃើញ សយ សែន ដោះខ្នោះជើងចេញ ហើយនាំអ្នកទោសចេញទៅក្រៅអគារដែរទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** លោកសាក្សី លោកដែលឃើញ សយ សែន ដោះសម្លៀកបំពាក់អ្នកទោសចេញពីខ្លួនដែរទេ គឺចេញពីខ្លួនសាកសពរបស់អ្នកទោសដែរទេ ក្រោយពីសម្លាប់ហើយ?

**ឆ៖** បាទ អត់ទេ។

**ស៖** លោកសាក្សី លោកដែលឃើញ សយ សែន យាមអ្នកទោសនៅពេលអ្នកទោសធ្វើការនៅខាងក្រៅគុកនោះដែរទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** លោកសាក្សី លោកដែលឃើញ សយ សែន នាំអ្នកទោសចេញពីបន្ទប់សួរចម្លើយទៅក្រោយពេលសួរចម្លើយហើយ?

**ផ៖** បាទ អត់ទេ។

[០៩:៥៨:២០]

**ស៖** លោកសាក្សី លោកដែលឃើញ សយ សែន ចែកបាយទឹកទៅឱ្យអ្នកទោសដែរទេ?

**ផ៖** ហ្នឹងឃើញចែកបាទ។

**ស៖** តើចំណុចចែកបាយទឹកនេះ តែចំណុចមួយហ្នឹងទេដែលលោកបានឃើញ សយ សែន ធ្វើអ៊ីចឹង ឬក៏ធ្លាប់បានឃើញ សយ សែន ធ្វើអ្វីក្រៅពីហ្នឹងទៀត?

**ផ៖** បាទ ឃើញតែចែកបាយទឹកជាមួយលោក យាយញ៉ូ និង យាយវ៉ាត់ បាទ។

**ស៖** លោកសាក្សី គឺសក្ខីកម្មរបស់លោកឆ្លើយថា ការចែកបាយទឹកនេះគឺលោកបានឃើញតែរឿងហ្នឹងមួយ -- ចំណុចនេះមួយគត់នៅឯក្រាំងតាចាន់ អ៊ីចឹងមែនទេ?

**ផ៖** បាទ។

**ស៖** ប្រធានបទចុងក្រោយរបស់ខ្ញុំ ខ្ញុំបានសួរសំណួរមួយចំនួនអំពីអ្វីដែលលោកបានឃើញ អ្វីដែលលោកបានឃើញផ្ទាល់ភ្នែក។ ឥឡូវនេះខ្ញុំសូមសួរទៅលោក ទៅលើរាងកាយសាកសពមួយទៀត។ នៅពេលនៅក្រាំងតាចាន់ លោកដែលធុំក្លិនស្អុីចេញមកពីសាកសពអ្នកទោសដែរទេ?

[១០:០០:០០]

**ផ៖** បាទ បញ្ហានេះវានៅផ្ទាល់ហ្នឹង អាចធុំបាទ ធុំក្លិនបាទ។

**ស៖** តើលោកធុំក្លិនស្អុីហ្នឹងលោក?

**ផ៖** ធុំក្លិនសាកសពតែម្តងបាទ។

**ស៖** ពេលដែលលោកធុំក្លិនហ្នឹង លោកធុំក្លិនពេលណាដែរ? ហើយក្លិនហ្នឹងវាខ្លាំងប៉ុនណាដែរ?

**ផ៖** បាទ ការធុំក្លិន វាស្អុយអសោចពេញទាំងភូមិហ្នឹងទឹកដីហ្នឹងតែម្តងបាទ។

**ស៖** លោកដឹងថា ក្លិនហ្នឹងមកពីណាដែរ?

**ផ៖** បាទ ក្លិនហ្នឹងមកពីរណ្តៅសាកសពហ្នឹងតែម្តងបាទ។

**ស៖** ទីតាំងពិតប្រាកដក្លិនដែលចេញមកពិតប្រាកដហ្នឹង ចេញពីរណ្តៅសាកសពនៅឯណាដែរ?

**ផ៖** នៅរង្វង់បរិវេណហ្នឹងតែម្តងបាទ។

**ស៖** សូមលោកបញ្ជាក់ទីតាំងឱ្យចំៗតែម្តង?

**ផ៖** បាទ ទីតាំងនោះមិនធំទេ ដីរបងក្នុង៧០ម៉ែត្របួនជ្រុងបាទ ខាងក្រៅប្រហែលជា៣០០

ម៉ែត្រប្អូនជ្រុងបាទ។

[១០:០២:១៩]

**ស៖** តើលោកដែលសួរទៅ តាអាន -- តាអាន់ ថាក្លិនហ្នឹងវាជាក្លិនអ្នកទោស ឬក៏ក្លិនចេញមកពីណា ឬក៏ក្លិនអ្នកទោសដែលគេសម្លាប់ ឬក៏ក្លិនអ្នកទោសដែលស្លាប់ដោយសារតែជំងឺ? ដែលសួរទៅតាអាន់ ចំណុចអស់នេះទេ?

**ឆ៖** បាទ ចំណុចហ្នឹងមួយ មិនអាចបានសួរគេទេបាទ។

**ស៖** ដូច្នេះ លោកអត់ដឹងអំពីក្លិនដែលលោកធុំហ្នឹង ថាវាចេញមកពីអ្នកទោសដែលគេសម្លាប់ ឬជាក្លិនដែលចេញពីអ្នកទោសដែលស្លាប់ដោយជំងឺដែលអីអ៊ីចឹងទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ភាគច្រើនគេនិយាយខាងក្រៅ គេតមកខាងក្រៅគេថា ក្លិនឆ្អែងាប់អ៊ីចឹងទៅ មាន់ងាប់អ៊ីចឹងទៅបាទ។

**ស៖** ខ្ញុំមិនដឹងថា ខ្ញុំយល់លោកបានត្រឹមត្រូវទេ លោកថា លោកធុំក្លិន ហើយខ្លះគេថាក្លិនសត្វងាប់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ប្រហែលនេះជាសំណួរមួយចម្លែកសម្រាប់លោកហើយ បើលោកមិនអាចឆ្លើយបាន មិនជាបញ្ហាអ្វីទេ។ ប៉ុន្តែលោកអាចញែកឲ្យដាច់ពីគ្នាបានទេ រវាងក្លិនសត្វស្អុយរលួយ ហើយនិងក្លិនសាកសពនោះ លោកអាចៗធុំក្លិនទៅញែកដាច់ពីគ្នារវាងក្លិនទាំងពីរនេះបានទេ?

**ឆ៖** បាទ យើងដើរទៅជួបគេផ្នែកខាងក្នុង គេថា នេះមាន់ងាប់ឯណាហ្នឹង ឬមួយក៏គេថា អ្វីឆ្អែងាប់ឯណាហ្នឹង ធុំក្លិនបាទ។ គេនិយាយតែប៉ុណ្ណឹងបាទ។

[១០:០៤:៥៨]

**ស៖** លោកសាក្សី តើលោកដឹងដែរឬទេថា ទីតាំងក្រាំងតាចាន់ហ្នឹង គឺធ្លាប់ជាផ្ទះរកប់ខ្មោចមុនឆ្នាំ៧៣? តើលោកដឹងពីចំណុចនេះទេ?

**ឆ៖** បាទ អត់ទេបាទ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអភ័យទោសលោក លោកស្រីចៅក្រម ខ្ញុំកំពុងតែពិនិត្យមើលសំណួររបស់ខ្ញុំ ហើយខ្ញុំមានប្រធានបទចុងក្រោយមួយទៀត។ ដូច្នេះខ្ញុំសូមអនុញ្ញាតដើម្បីពិភាក្សាទៅលើចំណុចនេះជាមួយលោក

សាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នេះគឺជាសក្ខីកម្មដែលកម្មាភិបាលរួមក្រុមរបស់លោក គឺសមមិត្ត ឌុច បានផ្ដល់ គឺសក្ខីកម្មនៅថ្ងៃ១៩ កុម្ភៈ E1/266.1 អង់គ្លេសមានលេខ 010 -- គឺអង់គ្លេសមានលេខ 01069768, បារាំង 01069755។ ឥឡូវនេះ ខ្ញុំសូមអានសំណួរគឺថាឥឡូវនេះខ្ញុំសូមបន្តសំណួរមួយ។ “តើលោកដឹងដែរឬទេនៅពេលណាមួយថា មានអ្នកទោសត្រូវបានគេបញ្ជូនចេញពីក្រាំងតាចាន់ទៅគុកផ្សេងដែរឬទេ? ចម្លើយ៖ បាទ គឺគេបញ្ជូនអ្នកទោសទៅកន្លែងផ្សេង ប៉ុន្តែខ្ញុំមិនដឹងថាទៅគុកណាទេ។ ខ្ញុំមិនដឹងអំពីអ្វីដែលកើតឡើងនៅទីតាំងក្រោយនេះទេ។ សំណួរ៖ តើគេបញ្ជូនអ្នកទោសទៅកន្លែងផ្សេងហ្នឹងញឹកញាប់ប៉ុនណាដែរ? ចម្លើយ៖ គឺថាវាមិនជាញឹកញាប់ទេ វាកើតឡើងនៅចុង៧៨ និងដើមចិត -- ចុង៧៧ ដើម៧៨។ សំណួរ៖ ថាតើទីតាំងនៅកន្លែងណាដែរ? ហើយអ្នកទោសហ្នឹងគេបញ្ជូនទៅណាដែរនៅក្នុងឆ្នាំ៧៨-៧៩ហ្នឹង? ចម្លើយ៖ គឺថាខ្ញុំមិនដឹងទេ”។ ដូច្នេះលោកសាក្សី ឥឡូវនេះខ្ញុំចង់សួរថាកាលពីម្សិលមិញលោកបាននិយាយបន្តិចបន្តួចអំពីចំណុចនេះ។ ប៉ុន្តែខ្ញុំចង់ឲ្យលោកនឹកឃើញឡើងវិញថា អ្នកទោសត្រូវបានគេបញ្ជូនចេញពីក្រាំងតាចាន់ ហើយបញ្ជូនទៅអ្នកទោសទៅកន្លែងផ្សេង។ ខ្ញុំចង់ដឹងថាតើគុកកន្លែងផ្សេងហ្នឹង ជាគុករបស់តំបន់ ឬក៏របស់ភូមិភាគនោះ?

[១០:០៧:៥៥]

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ចំណុចហ្នឹងមួយ ខ្ញុំអត់ដឹងដែរបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ ខ្ញុំនៅសល់សំណួរតែមួយពីរទៀតប៉ុណ្ណោះ មុននឹងខ្ញុំបញ្ចប់។ ដូច្នេះខ្ញុំគិតថាប្រហែលជាសហការីរបស់ខ្ញុំមានអ្វីបន្ថែមតទៅទៀត។

**លោក សួន វិសាល៖**

សូមគោរពលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី។

**សួរដោយលោក សួន វិសាល៖**

**ស៖** លោកសាក្សីបានឆ្លើយនៅចំពោះមុខសវនាការអស់រយៈពេលជិត២ថ្ងៃហើយ។ ហើយសំណួរជាច្រើនបានសួរលោក ហើយជាពិសេសគឺសហការីរបស់ខ្ញុំបានច្រើនហើយ។ ខ្ញុំមានសំណួរតែ

បីបួនសំណួរតែប៉ុណ្ណោះ នូវអ្វីដែលខ្ញុំគិតថាវាមិនទាន់ច្បាស់លាស់សម្រាប់ការបំភ្លឺតុលាការ។ សំណួរទី១ របស់ខ្ញុំ គឺទាក់ទងទៅនឹងការបញ្ជូន ការផ្លាស់ការងាររបស់អ្នកពីធ្វើទាហានស្រុកមកមន្ទីរក្រាំងតាចាន់។ តើនៅពេលដែលលោកផ្លាស់មកហ្នឹង គឺមេបញ្ជាការផ្ទាល់របស់លោកផ្លាស់មក ឬក៏អ្នកណាផ្សេង?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង គេមិនមែនផ្លាស់ទេ គេសុំកម្លាំងទៅជួយការពារនៅមន្ទីរក្រាំងតាចាន់។ គេថាតែប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលលោកមកធ្វើការនៅមន្ទីរក្រាំងតាចាន់ តើលោកមានទំនាក់ទំនងអ្វីទៀតនៅជាមួយនឹងបញ្ជាការរបស់លោកឬទេ?

[១០:០៩:៥៦]

**ឆ៖** បាទ អត់ទេ។

**ស៖** នៅមន្ទីរ នៅពេលដែលលោកមកដល់មន្ទីរក្រាំងតាចាន់ តើអ្នកណាជាអ្នកគ្រប់គ្រងរបស់លោក?

**ឆ៖** បាទ តាអាន់។

**ស៖** សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ឡើងវិញដែរ ថានៅពេលលោកមកដល់មន្ទីរក្រាំងតាចាន់ លោកបានឆ្លើយនៅចំពោះមុខសវនាការថា លោកមានតួនាទីជាអ្នកយាម នៅមន្ទីរហ្នឹងតែម្តង។ សួរថា តើលោកយាមហ្នឹង លោកជាធ្វើជាខ្លះយាម ឬក៏លោកដើរល្បាតជុំវិញកន្លែងទីលាននោះ?

**ឆ៖** បាទ ខ្ញុំនៅខាងក្រៅ បាទ នៅចំមាត់ច្រកតែម្តងបាទ ខាងក្នុងខ្ញុំអត់ដឹងទេ បាទ។

**ស៖** នៅពេលដែលលោកនៅខាងក្រៅនៅចំមាត់របងអ៊ីចឹង តើកម្លាំងផ្សេងទៀត នៅពេលយប់ ឬពេលថ្ងៃ ដើរយាមល្បាតជុំវិញទីបរិវេណមន្ទីរឃុំហ្នឹង ឬក៏លោកនៅចាំតែច្រកចូលហ្នឹង?

[១០:១១:២២]

**ឆ៖** បាទ ខ្ញុំល្បាតតែខាងក្រៅទេបាទ ហើយនិងរត់សំបុត្រតែម្តងបាទ។

**ស៖** បាទ សូមអរគុណ។ នៅរយៈពេលដែលលោកទៅធ្វើការនៅទីនោះជាអ្នកយាម ឬក៏នីរសារនៅទីនោះ តើលោកមានដែលបានចូលទៅក្នុងបរិវេណមន្ទីរអប់រំនោះទេ?

**ឆ៖** បាទ ក្នុងនោះ គេឲ្យចូល។ ដូចជាពេលហូបបាយ គេឲ្យដើរទៅតាមផ្លូវខាងលិចខាងកើតទិសខាងកើត ចំរោងបាយ គេអត់ឲ្យងាកឆ្វេងងាកស្តាំទេ គេឲ្យដើរត្រង់មកវិញបាទ។

**ស៖** ដូច្នេះ លោកមិនដែលបានដើរទៅមើលអគារ ឬក៏មើលកន្លែងផ្សេងទេ មានន័យអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរមួយទៀត នៅ -- លោកបានបញ្ជាក់ផងដែរ ថានៅក្នុងនោះមានបន្ទប់សួរចម្លើយ តើក្នុងពេលដែលលោកធ្វើការនៅទីនោះ លោកមានដែលបានទៅបន្ទប់សួរចម្លើយហ្នឹងទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** សូមអរគុណ។ សំណួរមួយទៀត គឺខ្ញុំចង់បញ្ជាក់ផងដែរ ថាតើនៅពេលដែលលោកធ្វើការនៅទីនោះ តើដែលមានឃើញគេចាប់ជនជាតិវៀតណាមទៅទីនោះទេ?

[១០:១៣:១១]

**ឆ៖** បាទ អត់ទេ។

**ស៖** ចំពោះជនជាតិកម្ពុជាក្រោម លោកដែលមានបានឮថាគេមានចាប់ទៅទីនោះទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** ចុះជនជាតិចាមយ៉ាងម៉េចដែរ ជនជាតិភាគតិចចាមនៅទីនោះ លោកដែលមានបានឃើញគេចាប់យកទៅទេ?

**ឆ៖** បាទ អត់ទេ។

**លោក សួន វិសាល៖**

លោកចៅក្រម ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៤១ នាទី)*

[១០:៤១:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក វ៉ាន់ សឿន ខ្ញុំមានសំណួរមួយទាក់ទងនឹងប្រវត្តិរូបរបស់លោក។ ខ្ញុំចង់ដឹងថា តើឪពុកម្តាយរបស់លោកនៅរស់ ឬក៏ស្លាប់? ដោយសារនៅក្នុងឯកសារ ដែលលោកបានផ្តល់កន្លងមកទាំងពីរ គឺឯកសារដែលមានលេខ D40/23 និងឯកសារ E319.1.33 មានចំណុចខ្វែងគ្នាទាក់ទងទៅនឹងប្រវត្តិរូបរបស់លោក។ ជាពិសេសគឺទាក់ទងទៅនឹងឪពុកម្តាយរបស់លោក។ ក្នុងឯកសារទី១ បញ្ជាក់ថាឪពុកម្តាយរបស់លោកហ្នឹងស្លាប់ហើយ ក៏ប៉ុន្តែនៅក្នុងឯកសារទី២ ថានៅរស់។ អ៊ីចឹងសូមលោកជួយបញ្ជាក់មើល៍?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ឪពុកម្តាយខ្ញុំស្លាប់ទើបតែបាន៧ខែទេបាទ ស្លាប់ទាំងពីរនាក់ មួយកន្លះខែស្លាប់មួយ មួយកន្លះខែស្លាប់មួយបាទ។ ១ខែស្លាប់ពីរនាក់តែម្តងបាទ។

**ស៖** ទើបតែសម្លាប់កន្លះខែមុន ឬមួយក៏យ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

[១០:៤៣:១០]

**ឆ៖** បាទ ស្លាប់បាន៧ខែហើយបាទ។

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែក្នុងឯកសារនេះ ធ្វើនៅឆ្នាំ២០០៧ ដែលថាឪពុករបស់លោកស្លាប់ ក៏ប៉ុន្តែដែលឯកសារដែលធ្វើក្រោយនៅក្នុងសំណុំរឿងផ្សេងនេះ បែរថានៅរស់វិញ តើចំណុចនេះ

វាជាកំហុសយ៉ាងម៉េចដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ក្រែងអ្នកយកព័ត៌មានច្រឡំទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ អំពីអ្នកដែលជាយោធាជាមួយលោកនៅក្នុងមន្ទីរក្រាំងតាចាន់ ដែលលោកបានថាធ្វើជាអ្នកយាម តើអ្នកទាំងអស់នោះមានជាប់សាច់ញាតិ ឬក៏មានអ្នកណាម្នាក់ជាប់សាច់ញាតិអ្វីនឹងលោកដែរទេ?

**ឆ៖** បាទ ជាប់ម្នាក់ដែរ។

**ស៖** អ្នកណាគេឈ្មោះអី? លោកអាចបញ្ជាក់ប្រាប់បានទេ?

**ឆ៖** បាទ ឈ្មោះ សាំង។

**ស៖** ត្រូវជាយ៉ាងម៉េច?

**ឆ៖** បាទ ត្រូវជាបងជីដូនមួយ។

[១០:៤៥:១១]

**ស៖** លោកដឹងថាគាត់ឈ្មោះ សាំង ហ្នឹង មានជាប់ពាក់ព័ន្ធអ្វីជាមួយនឹងតុលាការនេះដែរទេ?

**ឆ៖** បាទ អត់ដឹងដែរ។

**ស៖** លោកអាចបញ្ជាក់ឈ្មោះពេញរបស់គាត់បានទេ?

**ឆ៖** បាទ គេហៅថា សាំងៗ តែម្តងបាទ។

**ស៖** ឈ្មោះ សាំង ហ្នឹង សូត្រ សាំង ហ្នឹងមែនទេ?

**ឆ៖** បាទ។

**ស៖** បាទ ខ្ញុំសូមអានជូនលោកនូវឯកសារ E3/4846, ERN ជាភាសាខ្មែរ 00527731, ជាភាសាបារាំង 00943268, ជាភាសាអង់គ្លេស 00527778។ នៅក្នុងឯកសារនេះ ជាសម្ដីរបស់ សយ សែន ដែលគាត់បានបញ្ជាក់ថា "អ្នកដែលនៅយាមហ្នឹងគឺថា ជាបងប្អូនជីដូនមួយទាំងអស់ សុទ្ធតែបងប្អូនជីដូនមួយ។" ហើយគាត់បានបញ្ជាក់ថា លោក និងមានៗពីរនាក់ហ្នឹងជាៗបងប្អូនបង្កើត គឺឈ្មោះ សាំង ហ្នឹងឯង។ តើលោកដឹងពីទំនាក់ទំនងអ្នកយាមដទៃទៀតថា អ្នកទាំងអស់នោះជាបងប្អូនជីដូនមួយនឹងគ្នាដែរទេ អ្នកផ្សេងទៀត?

**ឆ៖** បាទ ក្នុងរឿងនេះ ដោយឡែកពីគ្នាទាំងអស់បាទ។ ដោយឡែកតែខ្ញុំ ហើយ សាំង ហ្នឹងបានបងប្អូនជីដូនមួយបាទ។

[១០:៤៨:១៨]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការសម្លាប់អ្នកទោសនៅក្រាំងតាចាន់ លោកបានបញ្ជាក់កន្លងមកថា ជួនកាលមួយខែម្តង ឬក៏ពីរខែម្តង ដែលមានការយកអ្នកទោសនៅក្រាំងតាចាន់យកទៅសម្លាប់។ ក៏ប៉ុន្តែ សយ សែន នៅក្នុងពេលដែលគាត់មកបង្ហាញសក្ខីកម្មនៅទីនេះដែលមានលេខឯកសារ E3 (សុំទោស) E1/256.1 ក្រោយម៉ោង ១៤:00:៤២ លោក សយ សែន គាត់បានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ជួនកាល១ខែមានវាយបួនដង ប្រាំដង ឬ១0ដងអីអ៊ីចឹងទៅ។ និយាយរឿងអត់មិនអត់ទេ នៅមានហូរហែអ៊ីចឹង អត់ខានទេ។ ប៉ុន្តែប្រភេទវាដូចតែគ្នា ឥតមានអ្នកណាមួយរាងដូចថា ឲ្យតែចំពោះអ្នកទោស បើថាអាពួកខាងគាត់គឺខាង គឺហ្នឹងបានរាងមើលភ្លឺៗ"។ (សុំទោស) ដោយសារអក្សរដូច្នេះខ្ញុំសូមបញ្ចប់ការដកស្រង់ត្រឹមប៉ុណ្ណេះ។ អ៊ីចឹង ខ្ញុំចង់បញ្ជាក់ចំណុចដែលខ្ញុំលើកអានអម្បាញ់មិញនេះ គឺគាត់លើកថា មួយខែមានវ៉ៃបួនដង ប្រាំដង ឬដល់១0ដង។ ចំណុចនេះ ខ្ញុំមើលឃើញថា វាមានចំនួនខុសគ្នាពីលោក តើលោកអាចឆ្លើយតបយ៉ាងម៉េចចំពោះសក្ខីកម្មនេះ?

**ឆ៖** បាទ ចំណុចហ្នឹង--

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយតប!

បាទសូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១០:៥០:៤៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំមិនបានស្តាប់ឮសាក្សីនិយាយនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងសវនាការនេះថា ការសម្លាប់ហ្នឹងមានប្រព្រឹត្តទៅគឺម្តង ឬក៏ពីរដងក្នុងមួយខែ ក៏ប៉ុន្តែគាត់ -- មេធាវីគាត់មិនបានដកស្រង់ឃ្លានៅក្នុងកំណត់ហេតុទេ។ សាក្សី គាត់បាននិយាយថា នៅពេលដែលមានសំបុត្រមកពីស្រុកហ្នឹង គឺមានការសម្លាប់មនុស្ស។ ដូច្នេះយើងមិនអាចសួរគាត់បែបនេះទេ។ ដូច្នេះ គួរតែយោងទៅលើកំណត់ហេតុជាក់លាក់ដែលផ្តល់លេខ ERN លេខទំព័រច្បាស់លាស់ ដើម្បីឲ្យដឹងថា តើគាត់បាននិយាយអ្វីខ្លះនៅក្នុងចម្លើយមុនៗរបស់គាត់នោះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារលេខ E319.1.33 ត្រង់សំណួរ១៨១ បាទ ជា

សក្ខីកម្មរបស់លោកដែលលោកបានឆ្លើយទៅនឹងសំណួរថា៖ “តើគេសម្លាប់អ្នកទោសញឹកញាប់ដែរឬទេ?” លោកឆ្លើយថា៖ “ជួនកាលមួយខែម្តង ឬជួនកាលពីរដង។” នេះជាសម្តីរបស់លោក លោកចាំបានទេ? ហើយបើលោកចាំបាន លោកអាចឆ្លើយនឹងសំណួររបស់ខ្ញុំដែលខ្ញុំសួរមុនអំមិញផងបាទ សូមអរគុណ។

**ឆ៖** បាទ ក្នុងចំណុចនេះ ខ្ញុំដឹងថា មួយខែម្តង ឬពីរដងតែប៉ុណ្ណោះ។ គ្រង់ដែលមួយខែរាប់អាទិត្យ រាប់ដងនោះ ខ្ញុំមិនបានដឹងទេបាទ។

[១០:៥២:៥១]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចូលទៅចំណុចមួយទៀត ទាក់ទងទៅនឹង តាសាន ។ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ លោកបានឆ្លើយនៅពេលរសៀល ម៉ោងមុនម៉ោងពីរ (សុំទោស) មុនម៉ោង ១៤:១៥:៥៧ បាទនៅខាងលើហ្នឹង។ លោកបាននិយាយថា ខ្ញុំសូមដកស្រង់ ថានៅពេលដែលមានសំណួរទាក់ទងទៅនឹង តាសាន លោកបានឆ្លើយថា “បាទ ខ្ញុំ” -- សូមដកស្រង់៖ “បាទ ខ្ញុំមិនបានច្បាស់ទេ ប៉ុន្តែជួបគាត់ហ្នឹង គឺឆ្នាំ៧៧”។ បាទនេះ ចង់និយាយអំពីពេលវេលាដែលលោកបានជួប តាសាន។ ហើយសួរទៀតថា៖ “អ៊ីចឹង នៅពេលដែលលោកជួបគាត់នៅឆ្នាំ១៩៧៧ហ្នឹង គាត់ជាគណៈស្រុកហើយ ឬក៏គាត់មានតួនាទីអ្វីផ្សេងនៅក្នុងឃុំស្រុកហ្នឹង?” លោកឆ្លើយថា៖ “បាទ ខ្ញុំជួបហ្នឹង គាត់ធ្វើចៅហ្វាយស្រុកត្រាំកក់ហ្នឹងតែម្តងបាទ”។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកបានជួប តាសាន ហ្នឹងនៅក្នុងកាលៈទេសៈអីដែរ លោកអាចជម្រាបអង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ ខ្ញុំជួប តាសាន ហ្នឹង ខ្ញុំមកលេងឪពុកម្តាយខ្ញុំនៅភូមិជ្រៃ ឃុំលាយបូរ ហើយខ្ញុំទៅសាលាឃុំលាយបូរ ហើយជួប តាសាន នៅកន្លែងហៅសហករណ៍កង១ នៅលាយបូរ បាទ។

**ស៖** លោកដឹងថា តាសាន ហ្នឹងគាត់ធ្វើអីដែរ នៅពេលដែលគាត់ លោកជួបគាត់នៅលាយបូរហ្នឹង?

[១០:៥៥:០២]

**ឆ៖** បាទ ជួបគាត់នៅពេលហូបបាយថ្ងៃបាទ។

**ស៖** ខ្ញុំចង់សួរបញ្ជាក់លោកថា តើលោកដឹងថា តាសាន ជាចៅហ្វាយស្រុកហ្នឹងដោយរបៀបណា?

**ឆ៖** បាទ ដឹងមកពីប្រជាជនប្រាប់ថា ចៅហ្វាយស្រុកត្រាំកក់យើងថ្មីហ្នឹងបាទ។

**ស៖** ប្រជាជន លោកស្គាល់ឈ្មោះគេទេ? ឬក៏គេមានការងារអ្វីដែលអាចបញ្ជាក់អំពី តាសាន បានទេ?

**ឆ៖** បាទ មិនអាចបញ្ជាក់បានទេ ពីព្រោះថ្នាក់ឃុំ និងថ្នាក់ស្រុក ហើយយើងក្មេងមិនអាចទៅជួបគេបានទេបាទ។

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ប្រជាជនដែលប្រាប់លោកថា តាសាន ជាគណៈស្រុកថ្មីហ្នឹងគាត់ឈ្មោះអី? ឬក៏គាត់មានភារកិច្ច មានការងារអីដែលអាចឲ្យគាត់ដឹងថា តាសាន ហ្នឹងជាគណៈស្រុកថ្មី? លោកអាចបញ្ជាក់បានទេ?

[១០:៥៦:៣៧]

**ឆ៖** បាទ ប្រជាជននោះមិនអាចបញ្ជាក់បានទេ ព្រោះគាត់ប្រជាជនដូចគ្នា ខ្សឹបពីមាត់មួយមាត់ពីរនៅក្នុងសហករណ៍ បាទ គ្រាន់តែដឹងប៉ុណ្ណឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ ចុះលោកមានដឹងជាលក្ខណៈផ្លូវការណាមួយ ដែលថា តាសាន ហ្នឹងជាចៅហ្វាយស្រុកត្រាំកក់ហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែដឹងច្បាស់ថា តាអាន់ ទៅដល់មន្ទីរក្រាំងតាចាន់គាត់និយាយថា "តាសាន ឥឡូវគេឡើងចៅហ្វាយស្រុក"។ គាត់និយាយតែប៉ុណ្ណឹងបាទ។

**ស៖** សូមលោកបញ្ជាក់ម្តងទៀត អ្នកណានៅក្រាំងតាចាន់ និយាយថា តាសាន ឡើងចៅហ្វាយស្រុក?

**ឆ៖** បាទ តាអាន់។

**ស៖** គាត់និយាយក្នុងឱកាសអីដែរ?

**ឆ៖** បាទ គាត់និយាយគាត់ដើរចូលទៅដល់ក្នុងពេលបាយហូបបាយហ្នឹង គាត់ប្រាប់ថា តាអាន់គាត់ថា "តាសាន ឥឡូវឡើងចៅហ្វាយស្រុកថ្មី!"។ គាត់គ្រាន់តែថាប៉ុណ្ណឹងទេបាទ។

[១០:៥៨:១០]

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់លោកទាក់ទងការងារនៅក្រាំងតាចាន់ ពីការប្រជុំវិញម្តង។ លោកធ្លាប់ចូលរួមប្រជុំជាមួយ តាអាន់ ឬក៏អ្នកផ្សេងទៀតនៅក្នុងក្រាំងតាចាន់ហ្នឹងដែរទេ? ការប្រជុំជាផ្លូវការ។

**ឆ៖** បាទ អត់ទេ។

**ស៖** លោកអាច -- លោកនិយាយថា អត់ហ្នឹង គឺអត់ក្នុងរយៈពេលតាំងពីលោកទៅធ្វើការនៅក្រាំងតាចាន់ហ្នឹងរហូតដល់ចុងបញ្ចប់ហ្នឹង គឺមិនដែលមានការប្រជុំជាផ្លូវការណាមួយជាមួយគ្នាទាល់តែសោះ ឬក៏មានការប្រជុំ តែលោកមិនចាំ?

**ឆ៖** បាទ តាំងពីខ្ញុំនៅក្រាំងតាចាន់មក មិនដែលបានប្រជុំជាមួយ តាអាន់ ទេបាទ។

**ស៖** ចុះកម្មាភិបាលផ្សេងទៀត ដែលលោកបាននិយាយអំពីអ្នកដែលជាបក្ខជនដទៃទៀតនោះ?

**ឆ៖** បាទ មានតែ ពេញ។

**ស៖** លោកចូលរួមប្រជុំញឹកញាប់ដែរឬទេជាមួយ តាពេញ ហ្នឹង?

[១១:០០:០០]

**ឆ៖** បាទ ក្នុងមួយខែម្ដង។

**ស៖** លោកអាចបញ្ជាក់អំពីកម្មវត្ថុនៃការប្រជុំបានទេថា គេប្រជុំអំពីអ្វីជាទូទៅ?

**ឆ៖** បាទ ប្រជុំនោះគេនិយាយអំពីហេតុផលការឃាមកាម និងការធ្វើស្រែ ការដាំបន្លែ រែកដីដំបូង និងរែកដីបាតត្រពាំង តែប៉ុណ្ណោះទេបាទ។

**ស៖** លោកមានដែលចូលរួមប្រជុំពីផែនការសម្លាប់អ្នកទោសដែរទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** បាទ សូមអរគុណ។ កាលពី -- ខ្ញុំសូមអានឯកសារលេខ E1/250.1 ជាកំណត់ហេតុសវនាការថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥។ លោក មាស សុខា គាត់បានផ្ដល់សក្ខីកម្មនេះនៅចំពោះមុខអង្គជំនុំជម្រះ នៅម៉ោង១២:០០:៥៣។ នៅពេលនុ៎ងគឺមេធាវី អង់តា ហ្គីសសេ គាត់ជាអ្នកសួរ។ ទាក់ទងទៅនឹងការប្រជុំមួយដែលមានការសម្លាប់មនុស្ស១០០នាក់ ហើយដែលមានការចូលរួមពីបុគ្គលិកទាំងអស់ បានន័យថាមានទាំងខាងកងការពារ មានទាំងខាងបក្ខជនហ្នឹងចូលរួមផងដែរ។ តើលោកចាំទេថាមានការប្រជុំបែបនេះនៅក្នុងពេលហ្នឹង គឺនៅឆ្នាំ១៩៧៧?

[១១:០២:៥៧]

**ឆ៖** បាទ ចំណុចហ្នឹងមួយ ខ្ញុំគេអត់ឲ្យចូលរួមទេបាទ។ ព្រោះតែគេប្រជុំដាក់ផែនការអី គេឲ្យខ្ញុំនៅខាងក្រៅបាទ។

**ស៖** លោកអាចបញ្ជាក់បានទេពីការដែលលោកមិនបានចូលរួម ហើយគេឲ្យលោកនៅខាងក្រៅហ្នឹងដោយសារតែអ្វីដែរ? ហើយចុះអ្នកយាមដទៃទៀតបានចូលរួមទេ?

**ឆ៖** បាទ ត្រង់ចំណុចនេះ ខ្ញុំមិនដឹងដែរ ពីព្រោះផែនការខ្ញុំច្រើននៅខាងក្រៅ ហើយនិងរត់សំបុត្រតែម្ដងបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងសក្ខីកម្មរបស់ មាស សុខា គាត់ -- តជាប់នឹងឯកសារអំមិញហ្នឹង ហើយម៉ោងដដែលហ្នឹង។ គាត់ឆ្លើយថា ខ្ញុំសូមដកស្រង់លើសំណួរ-ចម្លើយនេះ លោក១ សុខា គាត់ឆ្លើយ សូមដកស្រង់៖ "វត្តមានអ្នកសម្លាប់គឺដកតែ ឌុចធំ មួយ ហើយនិងអ្នកធ្វើបាយចង្ក្រានមួយតែពីរនាក់ហ្នឹង ឌុចធំ គាត់ដកខ្លួនចេញទៅក្រៅស្រុកក្រៅហើយ។ សួរ៖ អ៊ីចឹង ខ្ញុំអរគុណ។ អ៊ីចឹង ពេញ ហើយនិង ស៊ាន់ អីហ្នឹងមានវត្តមាននៅទីហ្នឹងដែរ អ៊ីចឹងមែនទេ? ហើយគាត់ឆ្លើយថា៖ អ៊ីចឹងមែន"។ បានន័យថា លោកមានវត្តមាន ដោយសារលោកប្រើឈ្មោះ ស៊ាន់ នៅពេលហ្នឹង គឺលោកមានវត្តមាននៅក្នុងការជួបប្រជុំហ្នឹងដែរ។ តើមានមានប្រតិកម្មយ៉ាងម៉េចចំពោះសក្ខីកម្មរបស់ មាស សុខា នេះ?

[១១:០៥:០៧]

**ឆ៖** បាទ ចំណុចនេះ សូមបញ្ជាក់ថា បើរឿងនេះ បើនិយាយ មាស សុខា ហ្នឹងនិយាយពិតមែនរហូតឲ្យទៅសួរដល់ម្ដាយវាតែម្ដងបាទ។ ព្រោះខ្ញុំនៅខាងក្រៅជាមួយម្ដាយ មាស សុខា ហ្នឹងរហូតបាទ មិនដែលពាក់ព័ន្ធនៅក្នុងចំណុចរឿងនេះទេបាទ។

**ស៖** លោកអាចបញ្ជាក់បានទេថា លោកនៅខាងក្រៅជាមួយម្ដាយ មាស សុខា រហូតហ្នឹង នៅយ៉ាងដូចម្ដេច?

**ឆ៖** ពីព្រោះខ្ញុំបានថាបញ្ជាក់ជាមួយម្ដាយ មាស សុខា ហ្នឹងពីព្រោះខ្ញុំចិញ្ចឹមបាយគាត់រហូត។ ហើយក៏ខ្ញុំមិនដែលពាក់ព័ន្ធជាមួយនឹង ជាមួយ ពេញ និង កងការពារផ្សេងទៀតដែរ ព្រោះចែកដាច់ពីគ្នាបាទ។

[១១:០៦:៣៧]

**ស៖** បាទ សូមអរគុណ។ លោកមានអីចង់បញ្ជាក់អំពីការឆ្លើយតបទៅនឹង មាស សុខា ហ្នឹងថែមទៀតទេ ទាក់ទងទៅនឹងវត្តមានរបស់លោកក្នុងការប្រជុំ តាមការឆ្លើយរបស់ មាស សុខា? មានអីចង់បន្ថែមទៀតទេ?

**ឆ៖** បាទ សូមបញ្ជាក់ថា មាស សុខា នេះគាត់ជាកូនរបស់លោកយាយ ញ៉ ហើយខ្ញុំនៅបន្ទប់ក្រៅរបងហ្នឹងតែម្នាក់ឯងទេ ហើយ មាស សុខា ហ្នឹងដេកផ្ទាល់នៅបន្ទប់ខ្ញុំតែម្ដង។ ហ្នឹងសូមជម្រាបប្រាប់លោក អស់លោកទាំងអស់ជ្រាបទាំងអស់គ្នាបាទ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំទាក់ទងទៅនឹងការប្រជុំដែល មាស សុខា គាត់ថា លោកចូលរួមប្រជុំដែរ ហើយលោកបានបដិសេធថា លោកមិនបានចូលរួមទេ។ អ៊ីចឹងខ្ញុំចឹងដឹងថា តើលោកមានអ្វីត្រូវឆ្លើយតបជាមួយនឹងសក្ខីកម្មរបស់ មាស សុខា ទៀតទេ ទាក់ទងការប្រជុំបាទ?

**ឆ៖** បាទ ទាក់ទងនឹងការប្រជុំវាពិតមែនហើយ ម្តងម្កាលជាមួយ ពេញ ហ្នឹង ប៉ុន្តែរឿងសម្លាប់មនុស្ស ខ្ញុំអត់ទេបាទ។

**ស៖** លោកអាចបង្ហាញថា តើមានហេតុផលអ្វីដែល មាស សុខា ឆ្លើយថាលោកចូលរួមក្នុងការប្រជុំសម្លាប់មនុស្សជាង១០០នាក់ហ្នឹងដែរទេ?

[១១:០៨:៤១]

**ឆ៖** បាទ បញ្ហានេះខ្ញុំក៏មិនអាចដឹងដែរ ដល់ មាស សុខា និយាយអ៊ីចឹង គាត់ជាអ្នកទោស ហើយគាត់និយាយថាសម្លាប់ដល់១០០នាក់ គាត់ឃើញពីណា ដឹងពីណា ក៏ខ្ញុំអត់ដឹងដែរបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងឯកសារ E319.1.33 ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក ត្រង់សំណួរ-ចម្លើយលេខ១៣១។ សំណួរថា សូមដកស្រង់៖ “តើលោកធ្លាប់ឮពាក្យខ្មាំងដែរឬទេ?” លោកឆ្លើយថា “ខ្ញុំធ្លាប់ឮ។ ខ្មាំងសំដៅទៅលើគូសត្រូវ នៅពេលដែលវ៉ៃជាមួយនឹងទាហាន លន់ នល់ ហើយពេលដែលខ្មែរក្រហមចាប់ទាហាន លន់ នល់ បាន គឺគេចាត់ទុកថាខ្មាំង។ សំណួរ៖ តើក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គេមាននិយាយអំពីពាក្យខ្មាំងទៀតដែរឬទេ? ចម្លើយ១៣២៖ អត់មានទេ”។ បាទ សូមបិទការដកស្រង់។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើមានហេតុផលអី ឬក៏មានមូលដ្ឋានអីដែលលោកអាចបញ្ជាក់ថា ក្រោយឆ្នាំ១៩៧៥ លោកលែង -- គេលែងនិយាយពាក្យថា “ខ្មាំង” ទៀតនោះ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ចំណុចហ្នឹងមួយ គេថា គោលនយោបាយ គេថាយើងខ្មែរទាំងអស់គ្នាបង្រួបបង្រួមគ្នា ដើម្បីកសាងជាតិ បាទ គេនិយាយតែប៉ុណ្ណឹងបាទ។

**ស៖** អ្នកណាគេអ្នកនិយាយ?

**ឆ៖** តាអាន់។

[១១:១១:១៥]

**ស៖** លោកមានស្តាប់ឮពីខាងណាទៀតទេ? មានខាងណានិយាយផ្សេងទៀតទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** តាអាន់ និយាយហ្នឹង ក្នុងឱកាសអីដែរ?

**ឆ៖** ពេលហូបបាយថ្ងៃត្រង់។

**ស៖** ជាការប្រជុំនិយាយប្រាប់បុគ្គលិក ឬមួយក៏ជាការនិយាយជាមួយលោកតែពីរនាក់ទេ?

**ឆ៖** តាអាន់ និយាយជាមួយ តាពេញ ប៉ុន្តែខ្ញុំហូបបាយនៅចុងតុម្ខាង ខ្ញុំស្ដាប់ឮ បាទ។

**ស៖** បាទ សូមអរគុណ។ ឯកសារដដែល ត្រង់ចំណួរចម្លើយ១៣៦ សំណួរថា សូមដកស្រង់៖ "តើលោកបានឮអ្វីខ្លះអំពីពួកកន្សែងស? ហើយតើលោកឮនៅពេលណា? ចម្លើយ១៣៦៖ ពួកកន្សែងស គឺចង់សំដៅទៅលើខ្មែរក្រហម -- អ៎! សូមទោស សំដៅលើខ្មែរក្រោម។ សំណួរ៖ តើកន្សែងស រួមជាមួយនឹង លន់ នល់ វ៉ៃជាមួយខ្មែរក្រហម ឬក៏រួមជាមួយនឹងខ្មែរក្រហមវ៉ៃជាមួយទាហាន លន់ នល់? ចម្លើយ១៣៧៖ រួមគ្នាជាមួយនឹង លន់ នល់ ដើម្បីវ៉ៃជាមួយនឹងខ្មែរក្រហម"។ បាទ សូមចប់ការដកស្រង់។ លោកអាចបញ្ជាក់អំពីក្រុមកន្សែងសនេះ ដែលលោកបញ្ជាក់ថា ជាកម្ពុជាក្រោម គេរួមគ្នាជាមួយ លន់ នល់ ដើម្បីវាយជាមួយខ្មែរក្រហម។ លោកដឹងថា គេរួមគ្នាយ៉ាងម៉េចដែរទេ?

[១១:១៣:៥៤]

**ឆ៖** បាទ កាលពីជំនាន់៧១, ៧២ ខ្ញុំនៅក្មេង ហើយមានបងជីដូនមួយខ្ញុំធ្វើទាហាននៅកម្ពុជាក្រោម បាទ។ ហើយមកឈរជើងនៅឃុំអូរចំបក់ ខាងលិចខេត្តតាកែវ ទីរួមខេត្តតាកែវហ្នឹង បាទ។ គេថា គេចូលក្រុមកន្សែងស ទ័ពកម្ពុជាក្រោម។ ខ្ញុំដឹងតែប៉ុណ្ណឹងទេបាទ។ ហើយកាលហ្នឹង វាមានវ៉ៃនៅប្រទាញប្រទង់ជាមួយខ្មែរក្រហម ហើយទ័ពកម្ពុជាក្រោមហ្នឹង សហការជាមួយទ័ពលន់នល់ បាទ។ ខ្ញុំដឹងតែប៉ុណ្ណឹង ព្រោះបងជីដូនមួយខ្ញុំនិយាយប្រាប់បាទ។

**ស៖** លោកមានបទពិសោធន៍ក្នុងការប្រយុទ្ធតទល់ជាមួយពួកកន្សែងសហ្នឹងទេ ក្នុង ឬក៏លោកបានដឹងពីការប្រយុទ្ធគ្នាណាមួយជាមួយពួកកន្សែងសហ្នឹងទេ ក្នុងពេលនុ៎ង ក្នុងពេលលោកនិយាយពីឆ្នាំ៧៣, ៧៤ អំមិញហ្នឹង?

**ឆ៖** បាទ កាលបងជីដូនមួយខ្ញុំនិយាយហ្នឹង គេនិយាយពីឆ្នាំ៧១, ៧២ បាទ។ ដល់រហូតដល់៧៣ ខ្ញុំអត់ដឹងដែរបាទ។

**ស៖** លោកដឹងពីអង្គការចាត់តាំងនៃពួកកន្សែងសហ្នឹងទេ ដែលលោកឆ្លើយបញ្ជាក់ថាជាខ្មែរក្រោមនោះ? ថាមានថ្នាក់ដឹកនាំជាអ្នកណា? ហើយគោលដៅនយោបាយគេយ៉ាងម៉េច លោកដឹងទេ?

**ឆ៖** បាទ អត់ទេ។

[១១:១៥:៥៣]

**ស៖** លោកដឹងថា ក្រុមកន្សែងសហ្នឹងមានរហូតដល់ពេលណាដែរ នៅមានដែលជាក្រុមប្រយុទ្ធហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរបាទ។

**ស៖** លោកមានស្គាល់អ្នកណាដែលជាសមាជិកនៃក្រុមកន្សែងសហ្នឹងដែរទេ រហូតមកដល់ពេលបច្ចុប្បន្នហ្នឹង?

**ឆ៖** បាទ ប៉ុល សោម មួយប៉ុន្តែបច្ចុប្បន្ននេះស្លាប់បាត់ទៅហើយបាទ នៅជិតផ្ទះខ្ញុំហ្នឹង វាធ្វើទាហាននៅកន្សែងសហ្នឹងតែម្តងបាទ។

**ស៖** លោកមានបានជួបនិយាយគ្នាជាមួយ សោម ហ្នឹង អំពីបេសកកម្មរបស់ក្រុមកន្សែងសហ្នឹងថាមាននិន្នាការនយោបាយបែបណាទេ?

**ឆ៖** បាទ អត់ដឹងដែរបាទ។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់ថា ហេតុអ្វីបានលោកដឹងថា ក្រុមកន្សែសហ្នឹងរួមគ្នាជាមួយទាហាន លន់ នល់ ដើម្បីវ៉ៃខ្មែរក្រហម?

**ឆ៖** បាទ ខ្ញុំឮតែគាត់និយាយថា កាលហ្នឹង លន់ នល់ សហការជាមួយក្រុមកន្សែងស។ កាលហ្នឹងវៀតណាមចូលមកទឹកដីកម្ពុជាយើងបាទ។ ខ្ញុំដឹងតែប៉ុណ្ណឹងបាទ។

[១១:១៧:៥៩]

**ស៖** បាទ ទាក់ទងឯកសារដដែល មកត្រង់សំណួរ-ចម្លើយលេខ១៤០។ សំណួរ សូមដកស្រង់៖ “នៅមន្ទីរសន្តិសុខក្រាំងតាចាន់ តើមានអ្នកទោសដែលជាអតីតទាហាន លន់ នល់ ដែរឬទេ? ឆ្លើយ៖ ពេលដែលខ្ញុំនៅធ្វើការ (សូមទោស) ពេលដែលខ្ញុំទៅធ្វើការនៅមន្ទីរសន្តិសុខក្រាំងតាចាន់ គឺអត់មានទេ”។ ខ្ញុំចង់សួរលោកថា ម៉េចបានលោកដឹងថាអត់មានទាហាន លន់ នល់ នៅក្រាំងតាចាន់? លោកអាចបញ្ជាក់បានទេពី ថាមានអ្វីដែលជាតឹកតាងបញ្ជាក់ថា អត់មានទាហាន លន់ នល់ ជាប់ទោសនៅក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់កន្លែងហ្នឹងថា បានខ្ញុំមិនដឹងពីព្រោះអ្នកទោសនាំមក មិនដឹងពីខាងណាទៅខាងណា។ អ៊ីចឹងខ្ញុំឆ្លើយថាមិនដឹងបាទ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់សាជាថ្មីត្រង់ចំណុចនេះ ដោយសារក្នុងចម្លើយរបស់លោក មិនមែន

បញ្ជាក់ -- មិនមែនឆ្លើយថា "មិនដឹងទេ" គឺបានន័យថា "អត់មាន អត់មានទេ"។ អ៊ីចឹងបានន័យថា លោកដឹងពីសមាសភាពអ្នកទោសនៅក្នុងក្រាំងតាចាន់។ លោកអាចបញ្ជាក់បានទេ ឬក៏លោកចង់កែប្រែចម្លើយរបស់លោកវិញ?

**ឆ៖** បាទ ត្រង់ចំណុចនេះ គ្រាន់ថាមិនដឹងសមាសភាពមកពីខាងណាៗទេបាទ។

[១១:២០:០៧]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារដដែល សំណួរបន្ទាប់ គឺក្នុងសំណួរចម្លើយលេខ១៤៣។ សំណួរ សូមដកស្រង់៖ "ក្នុងនាមលោកជាទាហានក្រោយពេលដែលទទួលបានជ័យជម្នះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកធ្លាប់បានទទួលការណែនាំអ្វី នៅពេលដែលជួបជាមួយនឹងអតីតទាហាន លន់ នល់ ដែរឬទេ? ចម្លើយលេខ១៤៣៖ "អត់ទេ គេគ្រាន់តែឲ្យបញ្ជូនទាហាន លន់ នល់ ទៅស្រុកវិញប៉ុណ្ណោះ"។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើលោកបានការអះអាងនេះពីណា? អ្នកណាជាអ្នកបញ្ជា ឬក៏ណែនាំលោកថាឲ្យបញ្ជូនទាហានលន់ នល់ ឬក៏ការចាត់ការណាមួយទាក់ទងនឹងទាហានលន់ នល់ ឲ្យទៅស្រុកវិញនេះ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទក្នុងហ្នឹង ខ្ញុំមិនបានដឹងដែរ បាទ។ គ្រាន់តែគេបញ្ជាក់ថាឲ្យទៅតាមគ្រួសារគេវិញទៅបាទ។ គេគ្រាន់តែបញ្ជាក់ តែប៉ុណ្ណឹងទេបាទ។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់បន្ថែមទាក់ទងពាក្យថា "ទៅស្រុក" គឺពាក្យថា "ទៅស្រុក" នេះបានន័យថាឲ្យទាហាន លន់ នល់ ទៅវិលត្រឡប់ទៅស្រុកកំណើតរបស់គេ តើអ៊ីចឹងមែនទេ?

[១១:២១:៤៧]

**ឆ៖** បាទ។

**ស៖** លោកដឹងពីណាមក នូវការណែនាំថាឲ្យទាហានលន់ នល់ អតីតទាហានលន់ នល់ វិលត្រឡប់ទៅស្រុកកំណើតរបស់គេនេះ?

**ឆ៖** បាទ ដឹងពីការនិយាយតៗគ្នាមកបាទ។

**ស៖** លោកអាចបញ្ជាក់ប្រភពច្បាស់ជាងហ្នឹងបានទេ ថាអ្នកណា? លោកដឹងនៅពេលណា? ក្នុងកាលៈទេសៈអី?

**ឆ៖** បាទ ក្នុងទាហានទីរួមខេត្តតាកែវអ៊ីចឹងចេញមកគឺថា តាមគ្រួសារគាត់តែម្តងទៅ បាទ។ គ្រាន់តែដឹងតែប៉ុណ្ណឹងទេបាទ។ រកបញ្ជាក់បន្ថែមពីថ្នាក់ណាបញ្ជា ឬមួយក៏បញ្ជាក់ពីណាទៅណា ក៏ខ្ញុំអត់

ដែរបាទ។

**ស៖** នៅពេលហ្នឹង លោកដឹងហ្នឹង គឺនៅក្នុងសមាសភាពរបស់លោកជាយុទ្ធជន ជាយោធារបស់ខ្មែរក្រហម តើអ៊ីចឹងមែនទេ?

**ផ៖** បាទ។

[១១:២៣:១៣]

**ស៖** តើអាចទេ ដែលថាមេបញ្ជាការរបស់លោកជាអ្នកណែនាំ ជាអ្នកនិយាយអំពីបញ្ហាអស់នេះ?

**ផ៖** បាទ ពួកគ្នាឯងតៗ គ្នាទេបាទ។

**ស៖** គ្នាឯងហ្នឹងគឺយោធាដូចគ្នាអ៊ីចឹង ឬមួយក៏យ៉ាងម៉េច លោកអាចបញ្ជាក់ផងទេ?

**ផ៖** បាទ យោធាដូចគ្នា។

**ស៖** បាទ ខ្ញុំសូមត្រឡប់ទៅឯកសារ E3/4846។ អម្បាញ់មិញខ្ញុំបានសួរលោកម្ដងរួចហើយទាក់ទងទៅនឹងញាតិភាពរបស់លោក ជាមួយនឹងឈ្មោះ សាំង។ ប៉ុន្តែខ្ញុំចង់បញ្ជាក់បន្ថែមទៀតត្រង់លេខ ERN ជាភាសាខ្មែរ 00527731, ភាសាបារាំង 00943268, 00-- (សុំទោស) ជាភាសាអង់គ្លេស 00527778។ នេះជាកិច្ចសម្ភាសន៍របស់លោក សយ សែន ជាមួយនឹងមន្ត្រីមជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ សុភារិទ្ធ។ ខ្ញុំសូមដកស្រង់៖ "សុភារិទ្ធ៖ សាំងហើស៊ុន អាហ្នឹងជាបងប្អូនបង្កើត? សែន៖ បងប្អូនបង្កើត។ សុភារិទ្ធសួរ៖ "ហើយហ្នឹងអ្នកសម្លាប់ហ្នឹងហ្មង? សែនគាត់ឆ្លើយ៖ អ្នកសម្លាប់ សុទ្ធតែអ្នកសម្លាប់។ អ្នកឃាតករហ្មង សុទ្ធតែអ្នកដៃដល់ គេហៅថាអ្នកដៃដល់នោះ។ សុភារិទ្ធ៖ ពេលដែលពូចូលទួលស្លែង អាហ្នឹង" សុំទោស ខ្ញុំសូមលុបចោលវិញ អាពាក្យថា "ចូលទួលស្លែង"។ ខ្ញុំសូមចប់ការដោះស្រង់ត្រឹម "គេហៅថាដៃដល់នោះ"។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើសក្ខីកម្មរបស់ សយ សែន នេះ ថាតើលោកមានប្រតិកម្មយ៉ាងម៉េច នៅពេលដែល សយ សែន បានហៅឈ្មោះ សាំង ហើយនិង ស៊ុន។ ហើយក្នុងនេះ បានមែនទែនទៅ គឺឈ្មោះ ស៊ាន់ ដែលជាលោកហ្នឹងឯង គេហៅថាជាបងប្អូនបង្កើតដែល ៗសាក្សីៗបានហៅលោកថា សាំង ហើយនិង ស៊ុន ហ្នឹងបងប្អូនបង្កើតបាទ ហើយជាអ្នកដៃដល់ជាឃាតករ ជាអ្នកសម្លាប់ បាទ។ លោកមានប្រតិកម្មយ៉ាងម៉េច ទាក់ទងទៅនឹងសក្ខីកម្មរបស់ សយ សែន នេះ?

[១១:២៧:៣៣]

**ឆ៖** បាទចម្លើយនេះ ត្រង់ចំពោះរូបខ្ញុំផ្ទាល់ អត់ទាល់តែសោះបាទ មិនបានចូលរួមនឹងគេទេបាទ។ សូមបដិសេធ។

**ស៖** អត់បានចូលរួមនេះ លោកចង់បញ្ជាក់ថា លោកមិនបានចូលរួមក្នុងការសម្លាប់ទាល់តែសោះ។ តើលោកនិយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ចុះលោកមានចូលរួមសកម្មភាពផ្សេងទៀត ឧទាហរណ៍ការដឹក បណ្ដើរអ្នកទោសទៅកន្លែងសម្លាប់ ឬក៏ការងារផ្សេងទៀតដែលទាក់ទងទៅនឹងការធ្វើទារុណកម្មចំពោះអ្នកទោសដែរទេ?

**ឆ៖** បាទ អត់ទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ។ សូមអរគុណលោកសាក្សី។

[១១:២៨:៣៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយមុននឹងចប់នៅព្រឹកនេះ យើង -- កាលពីព្រឹកមិញ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់មេធាវី នួន ជា សូមឱ្យអង្គជំនុំជម្រះធ្វើសវនាការជាអសាធារណៈ ស្ដាប់សក្ខីកម្មសាក្សី វ៉ាន់ សឿន ពាក់ព័ន្ធនឹងអង្គហេតុថាមានការបៀតបៀនផ្លូវភេទលើស្ត្រីភេទមួយរូបនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដើម្បីការពារសិទ្ធិជាសិទ្ធិឯកជនរបស់បុគ្គលដែលពាក់ព័ន្ធនឹងសំណួរ ដែលមេធាវីការពារក្ដី នួន ជា មានបំណងសួរចំពោះសាក្សី។ អង្គជំនុំជម្រះសម្រេចធ្វើសវនាការជាអសាធារណៈផ្នែកនៃការសវនាការស្ដាប់សក្ខីកម្មសាក្សី ពាក់ព័ន្ធនឹងបញ្ហានេះ។ ការអនុវត្តនេះ យោងតាមបទប្បញ្ញត្តិនៃវិធាន ៣១៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

ហើយបង្គាប់ឱ្យបុគ្គលិកផ្នែកសន្តិសុខអញ្ជើញសាធារណជនចាកចេញពីសាលសវនាការ។ បាទ ហើយក៏សូមជម្រាបជូនសាធារណជនផងដែរថា នៅរសៀលនេះអង្គជំនុំជម្រះធ្វើសវនាការ -- អង្គជំនុំជម្រះបើកកិច្ចប្រជុំរៀបចំសវនាការពិភាក្សាកិច្ចការជាសម្ងាត់ មិនមែនធ្វើសាធារណៈទេ សូមជ្រាប។ ហើយសូមផ្នែកខាងកងសន្តិសុខ រក្សាសណ្ដាប់ធ្នាប់នៅសាលសវនាការជាសាធារណៈ រួមទាំងក្រុមខាងអង្គភាពសាធារណៈរបស់ អ.វ.ត.ក ទាំងមូលជ្រាប និងចាត់វិធានការតាមភារកិច្ចរៀងៗខ្លួន។

បាទ អង្គជំនុំជម្រះបង្គាប់ឱ្យផ្នែកបុគ្គលិកសោតទស្សន៍ផ្ដាច់ប្រព័ន្ធសំឡេង និងរូបភាពចេញទៅ

សាលសវនាការជាសាធារណៈ ហើយប៉ុន្តែវាំងននទូវបើកដដែលដើម្បីសម្រួលដល់ការបកប្រែភាសា។ ហើយអង្គជំនុំជម្រះជម្រាបដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការនេះថា ដើមបណ្ដឹងរដ្ឋប្បវេណីអនុញ្ញាត -- អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីអង្គុយនៅទីនេះក្នុងអំឡុងពេលធ្វើសវនាការជាអសាធារណៈនេះ។ តែត្រូវរក្សាការសម្ងាត់ មិនត្រូវចែករំលែកព័ត៌មានជាលទ្ធភាពនៃសវនាការនេះទៅដល់បុគ្គលណាឡើយ។

សូមអញ្ជើញលោកមេ--

*(ចៅក្រមពិភាក្សាគ្នា)*

*(សវនាការសាធារណៈផ្អាកនៅម៉ោង ១១:៣១ នាទី)*

*(សវនាការអសាធារណៈបន្តពីម៉ោង ១១:៣២ នាទី រហូតដល់ម៉ោង ១១:៥១ នាទី)*